ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
**លេខ :** ...................................................

ថ្ងៃ ចន្ទ ៥ រោច ខែ ភទ្របទ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២០

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ឆ្លងសេចក្តីព្រាង "ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)"

នាព្រឹកថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០២០ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាង **"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)"** ដោយមានការអញ្ជើញចូលរួមពីសំណាក់ **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធានគណៈកម្មការអន្តរក្រសួងសិក្សារៀបចំផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប, **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា គណៈកម្មការកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ។

**"ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)"** សិក្សារៀបចំដោយគណៈកម្មការអន្តរក្រសួង ដឹកនាំដោយឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួងរៀបចំផែនការមេនេះ ត្រូវបានរំពឹងថានឹងក្លាយជាយន្តការដ៏មានសារៈសំខាន់ចាំបាច់ សម្រាប់ការឆ្លើយតបទៅនឹងស្ថានភាពនាពេលបច្ចុប្បន្នក៏ដូចជាអនាគត ឆ្លើយតបនឹងឥទ្ធិពលនៃជំងឺឆ្លងកូវីដ-១៩ (COVID-19) ជាពិសេស ត្រូវសម្រេចឱ្យបាននូវបំណងប្រាថ្នារួមរបស់រាជ-រដ្ឋាភិបាលដើម្បីជាអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តសៀមរាប ដូចខាងក្រោម៖

**ទី១៖** ខេត្តសៀមរាប គឺជាខេត្តទេសចរណ៍អន្តរជាតិដ៏គួរឱ្យចាប់អារម្មណ៍ និងមានការទទួលស្គាល់ជាលក្ខណៈជាសកលលើការអភិរក្ស និងកិច្ចគាំពារសម្បត្តិបេតិកភណ្ឌវប្បធម៌ និងបរិស្ថានធម្មជាតិ ដោយផ្តល់ជូននូវធនធានទេសចរណ៍ និងភាពទាក់ទាញជាច្រើនទៀត ។

**ទី២៖** ធានាឱ្យបាននូវផលប្រយោជន៍សង្គម-សេដ្ឋកិច្ច ជាអតិបរមាពីវិស័យទេសចរណ៍ ពោលគឺតំបន់ប្រវត្តិសាស្ត្រអង្គរ, តំបន់ទីក្រុងដែលមានស្ទឹងសៀមរាប, តំបន់ទន្លេសាប, ឧទ្យានជាតិភ្នំគូលែន និងតំបន់ជនបទដែលជាគោលដៅទេសចរណ៍ត្រូវតែភ្ជាប់ជាមួយការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។

**ទី៣៖** ខេត្តសៀមរាប ត្រូវតែជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព សំដៅទាក់ទាញភ្ញៀវទេសចរដែលមានគុណភាពមកកម្សាន្ត ម្តងហើយម្តងទៀត ស្នាក់នៅយូរ និងចំណាយច្រើន អាចបង្កើននូវចំណូលជូនប្រជាពលរដ្ឋមូលដ្ឋាន និងកសាងសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយបរិយាប័ន្ន ។

លើសពីនេះ, **"ផែនការមេសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)"** ក៏នឹងឆ្លុះបញ្ចាំងពីឆន្ទៈរបស់រាជរដ្ឋាភិបាលដែលចាត់ទុក **"វិស័យទេសចរណ៍ជាមាសបៃតង"** ក្នុងការចូលរួមដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច,

ដីឡូត៍លេខ៣ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ:+៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ:+៨៥៥ ២៣ ៨៨៤ ៩៧៤

ការលើកស្ទួយវប្បធម៌ជាតិ និងទ្រទ្រង់ដល់កិច្ចគាំពារបរិស្ថានប្រកបដោយប្រសិទ្ធភាពខ្ពស់ និងប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប និងតំបន់ជុំវិញ ដើម្បីប្រែក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព (Alternative Tourism/Quality Destination) មានការគ្រប់គ្រងលើការអភិវឌ្ឍវិស័យទេសចរណ៍ច្បាស់លាស់ និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់តំបន់អង្គរ និងធនធានធម្មជាតិឱ្យបានជាអតិបរមា សំដៅទាក់ទាញភ្ញៀវទេសចរមកកម្សាន្តច្រើនដង ពិសេស ភ្ញៀវទេសចរកម្រិតខ្ពស់ដើម្បីបង្កើននូវប្រភពចំណូលជូនជាតិ និងប្រជាពលរដ្ឋមូលដ្ឋាន ។ តាមការព្យាករណ៍ក្នុងឆ្នាំ ២០៣៥ ទេសចរណ៍អន្តរជាតិនាំមកនូវចំណូលចំនួន ៤,៧៦៥លានដុល្លារ និងទេសចរណ៍ជាតិ នាំមកនូវចំណូលចំនួន ១,២៨០លានដុល្លារ ។

ជារួម, ចក្ខុវិស័យរបស់ "**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)**" គឺ "**ការក្តាប់យកមកវិញនូវមោទនភាពជាគោលដៅទេសចរណ៍ចម្បងបំផុតរបស់វិស័យទេសចរណ៍កម្ពុជា និងជាគោលដៅទេសចរណ៍ចម្បងក្នុងតំបន់អាស៊ីអាគ្នេយ៍**" ។ ដើម្បីសម្រេចបានចក្ខុវិស័យខាងលើនេះ "**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប (២០២០-២០៣៥)**" បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន **០៧** រួមមាន៖

**១.** យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ទេសចរណ៍អាទិភាពខេត្តសៀមរាប,

**២.** យុទ្ធសាស្ត្រវិនិយោគទេសចរណ៍ និងការអភិវឌ្ឍរបៀងទេសចរណ៍ថ្មីៗក្នុងខេត្តសៀមរាប,

**៣.** យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ និងការតភ្ជាប់,

**៤.** យុទ្ធសាស្ត្រពង្រឹងគុណភាព និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍ខេត្តសៀមរាប,

**៥.** យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងបរិស្ថានខេត្តសៀមរាប,

**៦.** យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងការតភ្ជាប់គាំទ្រវិស័យទេសចរណ៍ខេត្តសៀមរាប, និង

**៧.** យុទ្ធសាស្ត្រអភិបាលកិច្ចសម្រាប់ទ្រទ្រង់ការអភិវឌ្ឍទេសចរណ៍ខេត្តសៀមរាប (ក្នុងនោះមានយុទ្ធសាស្ត្រចំនួន **៤៦** សកម្មភាពអនុវត្តចំនួន **១៥១** ដែលបានកំណត់រយៈពេលនៃការអនុវត្តៈរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង) ។

ជាមួយការបង្កើតយន្តការស្ថាប័ន អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Destination Management Organisations - DMO's) រួមសម្រាប់ខេត្តសៀមរាបហៅថា "**គណៈកម្មការអភិវឌ្ឍទេសចរណ៍សៀមរាប-អង្គរ**", នឹងមានអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក (Sub-DMO's)" អមគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរនេះ តាមតំបន់ទាំង ៦ ដូចជា៖ **១.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់ឧទ្យានជាតិភ្នំគូលែន, **២.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី, **៣.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់បេតិកភណ្ឌអង្គរ, **៤.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់ទីក្រុងសៀមរាប, **៥.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់បឹងទន្លេសាប និង **៦.** អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ (Sub-DMO) តំបន់ទីក្រុងសៀមរាបថ្មី (Grand Siem Reap) ក្រោមទម្រង់ជាតំបន់ទេសចរណ៍ពិសេស ដែលមានអ្នកអភិវឌ្ឍក្រោមទម្រង់ជា PPP ។

អង្គប្រជុំ បានពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី "**ការដាក់ឱ្យអនុវត្តផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២០-២០៣៥**" និងបានសម្រេចដូចខាងក្រោម៖

**ទី១.** គាំទ្រជាគោលការណ៍លើ "**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២០-២០៣៥**" និងសូមវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់ក្រុមការងារដែលបានរៀបចំផែនការនេះឡើង ។

**ទី២.** ស្នើឱ្យកែសម្រួល និងកាត់បន្ថយនូវខ្លឹមសារលម្អិត ដោយរំលេចតែចំណុចគោលធំៗជាយុទ្ធសាស្ត្រ ដើម្បីឱ្យផែនការមេនេះមានខ្លឹមសារខ្លី តែចំគោលដៅច្បាស់លាស់ជាមុន ។

**ទី៣.** ស្នើឱ្យក្រសួង-ស្ថាបន័ពាក់ព័ន្ធដែលជាសមាជិក សមាជិកាគណៈកម្មការអន្តរក្រសួង ពិនិត្យឱ្យបានលម្អិតលើផ្នែក ដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចរបស់ខ្លួន រួចបញ្ជូនផ្នែកនោះមកក្រុមការងារគណៈកម្មការបញ្ចូលទៅក្នុងផែនការ មេនេះ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្ត ។

**ទី៤.** សម្រេចឱ្យបង្កើតភ្ជាប់គ្នារវាង"**ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២០-២០៣៥**" និង "**ផែនការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងសៀមរាប**" ដែលរាជរដ្ឋាភិបាលបានសម្រេចរួចហើយ ។

ជាចុងក្រោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ ក៏បានថ្លែង អំណរគុណ និងវាយតម្លៃខ្ពស់ដល់គណៈកម្មការអន្តរក្រសួង និងក្រសួង-ស្ថាប័នពាក់ព័ន្ធបានសហការដ៏ល្អក្នុងការរៀបចំឯកសារ ដ៏មានសារៈសំខាន់នេះឡើង ដែលជាសេចក្ដីព្រាងផែនការមេនេះ ។ អង្គប្រជុំ សម្រេចប្រជុំឆ្លងម្ដងទៀតនៅចុងខែ តុលា ឆ្នាំ ២០២០ ក្រោយពីការកែសម្រួល មុននឹងគោរពជាក់ជូន **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីពិនិត្យ និងសម្រេចដ៏ខ្ពស់ ខ្ពស់ ។